ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ១០៩..... ប្រក/ដនស

# ប្រកាស

## ស្តីពី

## ការបង្កើត និង ដាក់ឱ្យប្រើប្រាស់ឯកសារបម្រើឱ្យការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធី នៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច
- បានឃើញប្រកាសលេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។



អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងព្រលិត ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660, Fax : (855) 023 215 277 e-mail : lm_c_lim @ Camnet.Com. Kh

## ស ម្រេ ច

ប្រការ១

ត្រូវការបង្កើត និងដាក់ឱ្យប្រើប្រាស់ នូវឯកសារដូចខាងក្រោម ដើម្បីបម្រើដល់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច អនុលោមតាមអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិ ដើមភាគតិច :

- ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវយកគំរូតាមឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច
- សេចក្តីជូនដំណឹងស្តីពីការចុះកំណត់ព្រំ ការវាស់វែង និងការវិនិច្ឆ័យ ដីសហគមន៍ជនជាតិដើមភាគតិច( ឧបសម្ព័ន្ធទី១)
- បញ្ជីរាយក្បាលដីសហគមន៍ជនជាតិដើមភាគតិច ( ឧបសម្ព័ន្ធទី២)
- សេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិច( ឧបសម្ព័ន្ធទី៣)
- សៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ( ឧបសម្ព័ន្ធទី៤)
- ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីសហគមន៍ជនជាតិដើមភាគតិច ( ឧបសម្ព័ន្ធទី៥) ។

**ប្រការ ២ .-**

សៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវរៀបចំជាបី (០៣) ច្បាប់ ដូចគ្នាទាំងទម្រង់ និងខ្លឹមសារ ដើម្បីរក្សាទុកមួយច្បាប់នៅរដ្ឋបាលសុរិយោដីថ្នាក់ជាតិ , មួយច្បាប់នៅរដ្ឋបាលសុរិយោដីថ្នាក់ខេត្ត និងមួយច្បាប់ទៀត នៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង-ស្រុក ។

ទម្រង់ និងទំហំ នៃសៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវបានកំណត់ដូចខាងក្រោម :

- ទំហំក្រដាស A 3
- កម្រាស់ ២០០ ទំព័រ
- មួយទំព័រសំរាប់ចុះមួយក្បាលដី ។

សៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវបានបង្កើតឡើងតាមឃុំ-សង្កាត់នីមួយៗ ដាច់ដោយឡែកពីគ្នា ។ ករណីក្បាលដីមានចំនួនលើសពីពីររយ រដ្ឋបាលសុរិយោដីអាចប្រើសៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ច្រើនក្បាល តាមការជាក់ស្តែង ។

**ប្រការ ៣ .-**

វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាព ត្រូវយកគំរូតាមឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងប្រើសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ បាន និងកំពុងប្រើប្រាស់សំរាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។

**ប្រការ ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ .-**

ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។𝟋

រាជធានីភ្នំពេញ .ថ្ងៃទី ០៩ ខែ[illegible] ឆ្នាំ ២០១១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងមហាផ្ទៃ
- គ្រប់សាលារាជធានី-ខេត្ត
  " ដើម្បីសូមជូនជ្រាប "
- អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ
- គ្រប់មន្ទីរដនសស.រាជធានី-ខេត្ត
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ